# ក្រមប្រតិបត្តិរបស់ Delta Galil

## គោលបំណង

ក្រមប្រតិបត្តិនេះបង្កើតឡើងដើម្បីកំណត់សេចក្តីតម្រូវអប្បបរមាស្តីពីការធ្វើអាជីវកម្មជាមួយក្រុមហ៊ុនបុគ្គលសម្ព័ន្ធនានារបស់ Delta Galil Industries Ltd. (“Delta Galil”)។ Delta Galil រំពឹងថាក្រុមហ៊ុនផ្គត់ផ្គង់ទាំងអស់នឹងធ្វើការវាយតម្លៃហានិភ័យដែលពាក់ព័ន្ធនឹងមាត្រាទាំងអស់ដែលបានកំណត់នៅក្នុងក្រមនេះ និងដើម្បីបង្ហាញគោលការណ៍នេះដល់ក្រុមហ៊ុនផ្គត់ផ្គង់ដែលសម្ភារ ឬធាតុចូលរបស់ខ្លួនត្រូវបានដាក់បញ្ចូលនៅក្នុងទំនិញដែលលក់មកឲ្យ Delta Galil ដើម្បីកាត់បន្ថយហានិភ័យយ៉ាងសកម្មជាមុនដោយកំណត់គម្លាត និងផ្នែកនៃការកែលម្អជាសក្តានុពល។

## កាតព្វកិច្ចផ្លូវច្បាប់

Delta Galil និងក្រុមហ៊ុនបុគ្គលសម្ព័ន្ធទាំងឡាយរបស់ខ្លួននឹងធ្វើអាជីវកម្មតែជាមួយអ្នកម៉ៅការ ក្រុមហ៊ុនផ្គត់ផ្គង់ អ្នកលក់ និងភ្នាក់ងារដែលទទួលសិទ្ធិប៉ុណ្ណោះ ដែលក្នុងន័យនេះហៅថា “ក្រុមហ៊ុនផ្គត់ផ្គង់” ដែលអនុវលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃយុត្តាធិការដែលត្រូវអនុវត្ត ដែលពួកគេប្រតិបត្តិការ និងក្នុងយុត្តាធិការដែលទំនិញរបស់ខ្លួនចូលក្នុងពាណិជ្ជកម្ម។ Delta Galil នឹងមិនអត់ឱនចំពោះការខកខានក្នុងការគោរពច្បាប់ណាមួយដោយនិយោជិក ឬដៃគូពាណិជ្ជកម្មរបស់ខ្លួនឡើយ និងតម្រូវឲ្យនិយោជិកនិងដៃគូរបស់ខ្លួនរាយការណ៍អំពីការរំលោភច្បាប់ ឬបទប្បញ្ញត្តិដែលមានការសង្ស័យជាបន្ទាន់។ ក្នុងករណីទាំងអស់ដែលមានការខ្វែងគំនិតគ្នារវាងក្រមនេះ ក្រមអតិថិជនដែលត្រូវអនុវត្ត និងច្បាប់នោះបទដ្ឋានខ្ពស់ជាងនេះនឹងត្រូវអនុវត្ត។

## តម្លាភាព

Delta Galil រំពឹងថានឹងមានតម្លាភាពពេញលេញនៅក្នុងគ្រប់រូបភាពទាំងអស់នៅពេលបំពេញការងាររួមគ្នា។ ក្រុមហ៊ុនផ្គត់ផ្គង់ទាំងអស់និងនិយោជិកត្រូវតែមានក្រមសីលធម៌នៅក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។ ក្រុមហ៊ុនផ្គត់ផ្គង់នឹងរក្សានៅនឹងកន្លែងសម្រាប់រយៈពេល 5 ឆ្នាំ, ឯកសារចាំបាច់ទាំងអស់ដែលត្រូវបង្ហាញអនុលោមភាពតាមបទដ្ឋានទាំងនេះ រួមមានជាអាទិ៍ សេចក្តីតម្រូវរក្សាទុកកំណត់ត្រាដែលខ្លួនព្រមព្រៀងជាមួយ Delta Galil។ Delta Galil នឹងចាត់វិធានការជាវិជ្ជមានដូចជាការត្រួតពិនិត្យទីកន្លែងផលិតនៅនឹងកន្លែងដោយមានការជូនដំណឹង និងមិនមានការជូនដំណឹង ដើម្បីតាមដានអនុលោមភាពតាមបទដ្ឋានទាំងនេះ។ ក្រុមហ៊ុនផ្គត់ផ្គង់ទាំងឡាយត្រូវតែអនុញ្ញាតឲ្យអ្នកតំណាងរបស់ Delta Galil មានលទ្ធភាពពេញលេញក្នុងការចូលទៅកាន់ទីតាំងផលិត ប្រើប្រាស់កំណត់ត្រាបុគ្គលិក និងជួបបុគ្គលិកដើម្បីធ្វើសម្ភាសន៍ជាសម្ងាត់ពាក់ព័ន្ធនឹងទស្សនកិច្ចពិនិត្យតាមដាន។ លើសពីនេះទៀត ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែឆ្លើយតបជាបន្ទាន់ចំពោះការសាកសួរសមហេតុផលពីអ្នកតំណាងរបស់ Delta Galil ពាក់ព័ន្ធនឹងប្រធានបទដែលបានបញ្ជាក់នៅក្នុងសវនកម្ម។ ការខកខានមិនបានផ្តល់លទ្ធភាពពេញលេញ ឬឆ្លើយតបចំពោះការសាកសួរសមហេតុផលអាចទទួលរងទណ្ឌកម្ម ឬបញ្ឈប់ទំនាក់ទំនងអាជីវកម្មជាមួយក្រុមហ៊ុនផ្គត់ផ្គង់។ លើសពីនេះទៀត Delta Galil ប្តេជ្ញាស្វែងយល់អំពីក្រុមហ៊ុនផ្គត់ផ្គង់របស់ខ្លួននៅគ្រប់កម្រិតទាំងអស់នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន។ Delta Galil រំពឹងថាក្រុមហ៊ុនផ្គត់ផ្គង់របស់ខ្លួននឹងបង្កើនការប្តេជ្ញាចិត្តនេះដោយជួយគូសវាសផែនទីអំពីខ្សែសង្វាក់ផ្គត់ផ្គង់ទាំងអស់ដែលផលិតទំនិញសម្រាប់ផ្គត់ផ្គង់ដល់ Delta Galil។

## ទំនាក់ទំនងការងារ

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែទទួលយក និងប្រកាន់ខ្ជាប់ចំពោះច្បាប់និងលក្ខខណ្ឌការងារនានាដែលគោរពបុគ្គលិក និង ការពារសិទ្ធិរបស់បុគ្គលិកនៅក្រោមច្បាប់និងបទប្បញ្ញត្តិសន្តិសុខការងារ និងសង្គមរបស់ជាតិនិងអន្តរជាតិឲ្យបានជាអប្បបរមា។ បុគ្គលិកទាំងអស់ត្រូវតែទទួលបានព័ត៌មានស្តីពីលក្ខខណ្ឌមូលដ្ឋានអំពីការងាររបស់ខ្លួនមុននឹងចេញពីផ្ទះ។

## ការមិនរើសអើង

ចំណែកឯ Delta Galil ទទួលស្គាល់ និងគោរពបំលែកវប្បធម៌ ការងារគួរតែផ្អែកលើសមត្ថភាព មិនមែនលើជំនឿ ឬលក្ខណៈផ្ទាល់ខ្លួនណាមួយផ្សេងឡើយ។ Delta Galil តាំងចិត្តមុតមាំងក្នុងការប្រព្រឹត្តដោយយុត្តិធម៌ និងស្មើភាពគ្នាចំពោះបុគ្គលិកទាំងអស់។ បេក្ខជននិងនិយោជិកត្រូវតែធ្វើការវាយតម្លៃទៅតាមសមត្ថភាព គុណវុឌ្ឍិ និងស្នាដៃរបស់ខ្លួន។ ក្រុមហ៊ុនផ្គត់ផ្គង់មិនត្រូវរើសអើងក្នុងការជ្រើសរើសបុគ្គលិក ផ្តល់ប្រាក់សំណង ការដំឡើងឋានៈ វិន័យ ការបញ្ឈប់ពីការងារ ឬការចូលនិវត្តន៍ ដែលរួមមានការរើសអើងផ្អែកលើក្រុមសង្គម ដើមកំណើតជាតិសាសន៍ ពូជសាសន៍ ភេទ លក្ខណៈភេទ សាសនា សញ្ជាតិ អាយុ ពិការភាព ឬលក្ខណៈផ្សេងទៀតឡើយ។

## ពលកម្មដោយបង្ខំ

ក្រុមហ៊ុនផ្គត់ផ្គង់មិនត្រូវប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំដែលរួមមានអ្នកជាប់ពន្ធនាគារ អ្នកជាប់កិច្ចសន្យា ការបញ្ចាំខ្លួនធ្វើការដោះបំណុល ឬទម្រង់ពលកម្មដោយបង្ខំផ្សេងទៀត។ មិនតម្រូវឲ្យបុគ្គលិកណាម្នាក់បង់ប្រាក់សម្រាប់ការងាររបស់ពួកគេឡើយ។ រាល់ការចំណាយ និងថ្លៃសេវាទាំងអស់ដែលពាក់ព័ន្ធនឹងការជ្រើសរើស ឬបណ្តុះបណ្តាលបុគ្គលិក ត្រូវតែចំណាយដោយនិយោជក មិនមែនកាត់ប្រាក់ពីបុគ្គលិកវិញឡើយ។ បុគ្គលិកត្រូវតែរក្សាការគ្រប់គ្រងឯកសារធ្វើដំណើររបស់ខ្លួន និងមានសេរីភាពពេញលេញក្នុងការធ្វើដំណើរ។ ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែធានានូវអវត្តមាននៃសូចនាករទាំងអស់ស្តីពីពលកម្មដោយបង្ខំដូចបានពណ៌នានៅក្នុងសូចនាកររបស់ ILO ស្តីពីពលកម្មដោយបង្ខំ។ សេចក្តីតម្រូវបន្ថែមមានបង្ហាញលម្អិតនៅក្នុងលិខិតបញ្ជាក់ពលកម្មដោយបង្ខំរបស់ Delta Galil ដែលក្រុមហ៊ុនផ្គត់ផ្គង់របស់ Delta Galil ទាំងអស់ត្រូវតែស្វែងយល់ និងចុះហត្ថលេខា។ ចំណុចមួយចំនួន និងទាំងអស់នៅក្នុងលិខិតបញ្ជាក់ពលកម្មដោយបង្ខំរបស់ Delta Galil ត្រូវបានដាក់បញ្ចូលនៅក្នុងក្រមនេះ។

## ពលកម្មកុមារ

ក្រុមហ៊ុនផ្គត់ផ្គង់មិនត្រូវជួលជនណាដែលមានអាយុក្រោម 15 ឆ្នាំ ឬនៅក្រោមអាយុបំពេញការងារតាមផ្លូវច្បាប់របស់ប្រទេស ឬនៅក្រោមអាយុបញ្ចប់កាតព្វកិច្ចសិក្សាអប់រំ ដែលករណីមួយណាក៏ដោយឲ្យតែខ្ពស់ជាង។ បុគ្គលិកដែលមានអាយុក្រោម 18 ត្រូវតែជ្រើសរើសឲ្យធ្វើការងារដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមូលដ្ឋានដែលទាក់ទងនឹងបុគ្គលិកវ័យក្មេង។

## សេរីភាពក្នុងការបង្កើតសមាគម និងការចរចារួមគ្នា

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែទទួលស្គាល់ និងគោរពសិទ្ធិរបស់បុគ្គលិកក្នុងការបង្កើតសមាគមដោយសេរី ចរចារួមគ្នា និងចាត់វិធានការការពារសិទ្ធិរបស់បុគ្គលិកដោយមិនមានការភ័យខ្លាចអំពីការជ្រៀតជ្រែក ការបំភិតបំភ័យ ការយាយីរ ឬការសងសឹកឡើយ។ លើសពីនេះទៀត ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែទទួលស្គាល់សិទ្ធិនេះនៅតាមប្រទេសដែលសិទ្ធិក្នុងការមានសេរីភាពបង្កើតសមាគម និងការចរចារួមគ្នាត្រូវបានរឹតត្បិតនៅក្រោមច្បាប់មូលដ្ឋាន។

## យន្តការបណ្តឹងតវ៉ាពីលក្ខខណ្ឌការងារដែលកំពុងបំពេញមុខងារ

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែធានាថាបុគ្គលិកអាចប្រើប្រាស់យន្តការបណ្តឹងតវ៉ាពីលក្ខខណ្ឌការងារយ៉ាងមានប្រសិទ្ធភាព ដែលរួមមានមធ្យោបាយរាយការណ៍ច្រើនយ៉ាង ដែលយ៉ាងហោចណាស់មានមធ្យោបាយមួយមានលក្ខណៈសម្ងាត់។

## ការយាយី និងការរំលោភបំពាន

បុគ្គលិកមានសិទ្ធិធ្វើការងារនៅក្នុងបរិស្ថានមួយដែលមិនមានការរំលោភបំពានដោយពាក្យសម្តី ផ្លូវចិត្ត និងផ្លូវកាយ ការបំភិតបំភ័យ ការយាយីផ្លូវភេទ ការកេងប្រវ័ញ្ច ការវាយប្រហារ ឬការប្រមាថមាក់ងាយដោយបុគ្គលិកផ្សេង បុរស ឬស្ត្រី ដោយមិនគិតពីតួនាទីរបស់ខ្លួននៅក្នុងក្រុមហ៊ុន ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែប្រព្រឹត្តចំពោះបុគ្គលិកទាំងអស់ដោយសេចក្តីថ្លៃថ្នូរ និងការគោរព។

DELTA GALIL INDUSTRIES LTD.

## ម៉ោងបំពេញការងារ និងការសម្រាក

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែធានាថាម៉ោងបំពេញការងាររបស់បុគ្គលនឹងមិនលើសពីការកំណត់របស់ច្បាប់ស្តីពីម៉ោងធម្មតា និងម៉ោងលើសនៅក្នុងយុត្តាធិការដែលពួកគេផលិតឡើយ។ សប្តាហ៍បំពេញការងារធម្មតាមិនលើសពី 48 ម៉ោងឡើយ។ ការងារលើសម៉ោងទាំងអស់ត្រូវតែមានការព្រមព្រៀងគ្នា។ ក្រុមហ៊ុនផ្គត់ផ្គង់មិនត្រូវស្នើសុំឲ្យធ្វើការម៉ោងលើសជាទៀងទាត់ និងត្រូវផ្តល់ប្រាក់ចំពោះការបំពេញការងារម៉ោងលើសទាំងអស់ក្នុងអត្រាមួយពិសេស។ នៅក្នុងកាលៈទេសៈវិសាមញ្ញ ចំនួនម៉ោងបំពេញការងារធម្មតា និងម៉ោងលើសក្នុងមួយសប្តាហ៍មិនត្រូវលើសពី 60 ម៉ោងឡើយ។ បុគ្គលិកទាំងអស់មានសិទ្ធិឈប់សម្រាកយ៉ាងតិចបំផុតមួយថ្ងៃដែលស្មើនឹង 24 ម៉ោងបន្តបន្ទាប់នៅរៀងរាល់រយៈពេលប្រាំពីរថ្ងៃ។

## ប្រាក់សំណង

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែទូទាត់ប្រាក់ដល់បុគ្គលិករបស់ខ្លួនឲ្យបានសមរម្យដោយផ្តល់កញ្ចប់ប្រាក់សំណងដែលអនុលោមតាមបទដ្ឋានអប្បបរមាដែលចែងក្នុងច្បាប់ ឬប្រាក់ខែទូទៅ ទោះជាមួយណាខ្ពស់ជាងក៏ដោយ និងផ្តល់អត្ថប្រយោជន៍ពិសេសបន្ថែមដែលតម្រូវដោយច្បាប់ឬកិច្ចសន្យា។ បុគ្គលិកត្រូវតែទទួលបានប្រាក់សំណងពេញសម្រាប់ម៉ោងលើសដោយអនុលោមតាមច្បាប់មូលដ្ឋាន ហើយបុគ្គលិកម្នាក់ៗត្រូវទទួលបានគណនេយ្យច្បាស់លាស់ និងជាលាយលក្ខណ៍អក្សរសម្រាប់រយៈពេលបើកប្រាក់នីមួយៗ។ ត្រង់កន្លែងដែលប្រាក់សំណងមិនឆ្លើយតបតាមតម្រូវការរបស់បុគ្គលិក និងផ្តល់ប្រាក់ចំណូលឆន្ទានុសិទ្ធមួយចំនួន ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវចាត់វិធានការសមស្របដែលស្វែងយល់ថែមទៀតពីកម្រិតនៃប្រាក់សំណងដែលឆ្លើយតបនឹងតម្រូវការរបស់បុគ្គលិក។

## សុខភាពនិងសុវត្ថិភាព

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែមានប្រព័ន្ធនៅនឹងកន្លែងដើម្បីកំណត់ បង្ការ និងកាត់បន្ថយហានិភ័យយ៉ាងសកម្មជាមុនចំពោះសុវត្ថិភាពរបស់បុគ្គលិកទាំងអស់។ ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែផ្តល់ជូនបុគ្គលិករបស់ខ្លួននូវបរិស្ថានបំពេញការងារស្អាត មានសុវត្ថិភាព និងសុខភាព ដែលបង្កើតឡើងដើម្បីបង្ការគ្រោះថ្នាក់ និងរងរបួសចំពោះសុខភាពដែលកើតចេញពី និងកើតឡើងនៅអំឡុងពេលបំពេញការងារ ឬដោយសារតែប្រតិបត្តិការគ្រឿងបរិក្ខាររបស់និយោជក។ ប្រការនេះរួមមានការការពារឲ្យផុតពីអគ្គិភ័យ គ្រោះថ្នាក់ និងសារធាតុពុលនានា។ ភ្លើងបំភ្លឺ កម្តៅ និងប្រព័ន្ធខ្យល់ចេញចូលត្រូវតែមានគ្រប់គ្រាន់។ ក្រុមហ៊ុនផ្គត់ផ្គង់ចាំបាច់ត្រូវតែគោរពតាមបទដ្ឋានដែលត្រូវអនុវត្ត និងកំណត់ដោយច្បាប់ទាំងអស់សម្រាប់សុវត្ថិភាព និងសុខភាពកន្លែងការងារនៅតាមប្រទេស និងសហគមន៍នានាដែលពួកគេប្រតិបត្តិការ។ ដែលមានផ្តល់ជូនកន្លែងស្នាក់នៅដល់បុគ្គលិក អនុវត្តស្តង់ដារដូចគ្នា។

## បរិស្ថាន

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែចាត់ចែង និងបំពេញការងារដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថានដូចជាថាមពល ទឹក កាកសំណល់ ទឹកកខ្វក់ ការបញ្ចេញខ្យល់ និងសារធាតុគីមី។ ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិទាំងអស់ដែលពាក់ព័ន្ធនឹងការការពារបរិស្ថាននៅតាមប្រទេសដែលពួកគេប្រតិបត្តិការ។ ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែទទួលយកវិធានការប្រកបដោយការទទួលខុសត្រូវក្នុងការសម្រាលផលប៉ះពាល់អវិជ្ជមានដែលក្រុមហ៊ុនផ្គត់ផ្គង់បញ្ចេញនៅក្នុងបរិស្ថាន។

## សន្តិសុខ

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែបង្កើតទម្រង់ការសន្តិសុខដើម្បីទប់ស្កាត់ការនាំចេញនូវទំនិញលាក់លៀមទៅកាន់បរទេស។ ទំនិញទាំងនេះរួមមានថ្នាំញៀន ភ្នាក់ងារជីវសាស្ត្រ គ្រឿងផ្ទុះ អាវុធ រូបធាតុវិទ្យុសកម្ម វត្ថុខុសច្បាប់ និងទំនិញរត់ពន្ធដទៃទៀត។ Delta ទទួលស្គាល់គោលការណ៍ណែនាំអំពី CTPAT របស់គយ និងក្រុមការពារព្រំដែនសហរដ្ឋអាមេរិក (CBP)

សម្រាប់ក្រុមហ៊ុនផលិតបរទេសនានាថាជាលក្ខខណ្ឌតម្រូវអប្បបរមាដែលត្រូវអនុវត្តចំពោះប្រទេសនាំចូលទំនិញទាំងអស់។

សិទ្ធិស្ត្រី

ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវតែធានាថាបុគ្គលិកស្ត្រីនឹងទទួលបានប្រាក់បំណាច់ដែលរួមមានអត្ថប្រយោជន៍នានា ការប្រព្រឹត្តិដោយស្មើភាព ការវាយតម្លៃស្មើភាពចំពោះគុណភាពការងារ ឱកាសស្មើគ្នាក្នុងការបំពេញមុខតំណែងទាំងអស់ដែលបើកចំហដល់បុគ្គលិកជាបុរស។ ការធ្វើតេស្តរកមើលផ្ទៃពោះមិនមែនជាលក្ខខណ្ឌការងារ ឬមិនមែនជាការទាមទារចំពោះបុគ្គលិកឡើយ។ បុគ្គលិកដែលសម្រាកលំហែរមាតុភាព (ក្នុងរយៈពេលកំណត់ដោយច្បាប់មូលដ្ឋាននិងច្បាប់ជាតិ) នឹងមិនប្រឈមនឹងការបណ្តេញចេញ ឬការគំរាមកំហែងអំពីការបណ្តេញចេញ បាត់បង់អតីតភាពការងារ ឬការកាត់ប្រាក់ខែ និងអាចត្រឡប់ចូលបម្រើការងារដើមរបស់ខ្លួនវិញដោយទទួលបានប្រាក់ខែនិងអត្ថប្រយោជន៍ដូចមុនដដែល។ មិនត្រូវបង្ខិតបង្ខំ ឬដាក់សម្ពាធឲ្យបុគ្គលិកប្រើប្រាស់ថ្នាំពន្យារកំណើតឡើយ។ មិនត្រូវដាក់ឲ្យបុគ្គលិកទទួលរងវត្ថុគ្រោះថ្នាក់ ដូចជាការ និងសារធាតុរំលាយដែលអាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់ពួកគេដែលរួមមានសុខភាពបន្តពូជជាដើម។ ក្រុមហ៊ុនផ្គត់ផ្គង់ត្រូវផ្តល់សេវា និងកន្លែងស្នាក់នៅសមស្របដល់បុគ្គលិកស្ត្រី ដែលមានផ្ទៃពោះ។

ការម៉ៅការបន្ត

ក្រុមហ៊ុនផ្គត់ផ្គង់មិនត្រូវប្រើប្រាស់អ្នកម៉ៅការបន្តដើម្បីផលិតផលិតផលសម្រាប់ Delta Galil ឬផលិតសមាសភាគគ្រឿងដោយមិនមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពី Delta Galil ឡើយ និងល្គឹកណាតែអ្នកម៉ៅការបន្តបានព្រមព្រៀងអនុវត្តតាមកម្រប្រតិបត្តិនេះប៉ុណ្ណោះ។

ការរំលោភបំពានគោលការណ៍ទាំងនេះនឹងត្រូវបានដោះស្រាយឲ្យបានសមស្របតាមការចំណាយរបស់ក្រុមហ៊ុនផ្គត់ផ្គង់។ Delta Galil រក្សាសិទ្ធិចាត់វិធានការចាំបាច់ដើម្បីធានានូវអនុលោមភាពជាមួយបទដ្ឋានទាំងនេះនៅពេលអនាគត។ ការខកខានក្នុងការគោរពតាមបទដ្ឋានទាំងនេះជាចុងក្រោយនឹងនាំទៅដល់ការបញ្ឈប់នូវទំនាក់ទំនងរវាងក្រុមហ៊ុន Delta Galil និងក្រុហ៊ុនផ្គត់ផ្គង់ដែលទទួលសិទ្ធិ។